ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកៅស៊ូ

# សេចក្តីណែនាំ
## ស្តីពី
## វិធានការការពារនិងទប់ស្កាត់ការឆ្លងរាតត្បាត នៃជំងឺកូវីដ-១៩ (Covid-19)

ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាល និងតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល ក្នុងការទប់ស្កាត់ការឆ្លងរាតត្បាត នៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍សហគមន៍២០ កុម្ភៈ និងដើម្បីការពារសុខុមាលភាព សុវត្ថិភាពមន្ត្រីរាជការ អគ្គនាយកដ្ឋានកៅស៊ូ សូមធ្វើការណែនាំដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានកៅស៊ូទាំងអស់ ចូលរួមអនុវត្តវិធានការដូចខាងក្រោម៖

១-លោកប្រធាននាយកដ្ឋានទាំងអស់ ត្រូវធ្វើការតាមដាននិងជូនដំណឹងដល់មន្ត្រីរាជការក្រោមឱវាទឱ្យធ្វើការតាមដានសុខភាពជាប្រចាំ ដោយមានទំនួលខុសត្រូវខ្ពស់ ព្រមទាំងត្រូវបង្កើនការប្រុងប្រយ័ត្ន រក្សាអនាម័យ ដោយត្រូវលាងដៃនឹងសាប៊ូ ឬទឹកអាល់កុលជាប្រចាំ ពាក់ម៉ាស់ និងរក្សាគម្លាតសុវត្ថិភាពសង្គមឱ្យបានត្រឹមត្រូវតាមវិធានការណែនាំរបស់ក្រសួងសុខាភិបាល។

២-សូមមន្ត្រីរាជការទាំងអស់កុំធ្វើដំណើរទៅទីឆ្ងាយឬទីប្រជុំជនដែលមានមនុស្សច្រើន ក្នុងករណីមិនមានការចាំបាច់បន្ទាន់ និងត្រូវអនុវត្តជាប្រចាំនូវវិធានការការពារកូវីដ-១៩ "៣ការពារ" និង "៣កុំ" ឱ្យបានហ្មត់ចត់។

៣-ក្នុងករណីមន្ត្រីរាជការណាម្នាក់បានជាប់ពាក់ព័ន្ធឬមានទំនាក់ទំនងជាមួយបុគ្គលដែលវិជ្ជមានកូវីដ-១៩ ឬមានការសង្ស័យដោយមានរោគសញ្ញាស្រដៀងនឹងជំងឺកូវីដ-១៩ សាមីខ្លួនត្រូវដាក់ខ្លួននៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ និងត្រូវរាយការណ៍មកថ្នាក់ដឹកនាំ ឬទូរស័ព្ទទៅលេខ១១៥ជាបន្ទាន់។

៤-បន្តអនុវត្តវិធានការកាត់បន្ថយមន្ត្រីមកបំពេញការងារ និងវិធានការនានាដែលបានកំណត់ក្នុងសេចក្តីណែនាំស្តីពីការចាត់វិធានការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩(Covid-19) ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៥-មន្ត្រីរាជការដែលមកបំពេញការងារ ត្រូវធ្វើការវាស់កម្តៅតាមដានសុខភាពនិងស្កេន QR Code "ទប់ស្កាត់កូវីដ-១៩" នៅច្រកចេញ-ចូលឱ្យបានត្រឹមត្រូវ។

ទទួលបានសេចក្តីណែនាំនេះ សូមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ក្រោមឱវាទទាំងអស់ ត្រូវចូលរួមសហការអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ........................ ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី.....១៧..... ខែ.....មិថុនា..... ឆ្នាំ២០២១
**អគ្គនាយកដ្ឋានកៅស៊ូ**

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
National Road No. 6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០
Phone: (855) 23 6722 590, Email: gdr.maff@gmail.com